ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៦៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋ នូវទីតាំងដី សម្រាប់ការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ-បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១.-**

ត្រូវបានកំណត់បរិវេណដី សម្រាប់ធ្វើការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ ដែលមានទីតាំងស្ថិតនៅភូមិអូរ ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

**មាត្រា២.-**

ត្រូវបានធ្វើចំណាត់ថ្នាក់បរិវេណដី ដូចមានបញ្ជាក់ក្នុងប្លង់ឧបសម្ព័ន្ធ ដែលមានផ្ទៃក្រឡាសរុប ៥,៣០ ហិកតា ជាប្រភេទដីមានលក្ខណៈសម្បត្តិជាទ្រព្យសាធារណៈរបស់រដ្ឋ ដែលមានទីតាំងស្ថិតនៅភូមិអូរ ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ប្រកបដោយរបបគតិយុត្ត ដូចមានចែងក្នុងមាត្រា ១៥, មាត្រា ១៦, មាត្រា ១៧ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ និងមាននិយាមការដូចខាងក្រោម:

| ID. | Northing | Easting |
|---|---|---|
| P1 | 1198435.27 | 601709.14 |
| P2 | 1198442.53 | 601638.97 |
| P3 | 1198449.79 | 601568.81 |
| P4 | 1198457.06 | 601498.64 |
| P5 | 1198513.88 | 601490.11 |
| P6 | 1198570.71 | 601481.58 |
| P7 | 1198627.53 | 601473.04 |
| P8 | 1198684.36 | 601464.51 |
| P9 | 1198695.94 | 601531.85 |
| P10 | 1198707.53 | 601599.19 |
| P11 | 1198719.11 | 601666.53 |

**មាត្រា៣.-**

រាល់ការទន្ទ្រានយកដី ការដោះដូរ ការទិញលក់ ឬការផ្ទេរកម្មសិទ្ធិ ការចេញបណ្ណ័សំគាល់សិទ្ធិកាន់កាប់នៃអចលនវត្ថុទាំងឡាយតាមគ្រប់រូបភាពទាំងអស់ ទោះស្របច្បាប់ក៏ដោយ ដែលស្ថិតនៅក្នុងបរិវេណដីបង្កកដូចបានពណ៌នាខាងលើនេះ និងការចេញលិខិតអនុញ្ញាតឱ្យសាងសង់សំណង់ថ្មី ត្រូវបានហាមឃាត់ លើកលែងតែការផ្ទេរកម្មសិទ្ធិសម្រាប់បំរើផលប្រយោជន៍សាធារណៈ ។

រាល់ការបំពានលើបទប្បញ្ញត្តិ ដូចមានចែងខាងលើ អ្នកប្រព្រឹត្តល្មើសនឹងទទួលទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា ២៥៩ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ ។

**មាត្រា៤.-**

ម្ចាស់កម្មសិទ្ធិ ឬភោគីនៃដីឡូតិ៍ ក្នុងបរិវេណដីដែលនឹងត្រូវផ្ទេរប្រគល់ជូនរដ្ឋ ដើម្បីជាប្រយោជន៍សាធារណៈសម្រាប់ការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ នឹងទទួលបាននូវការទូទាត់សំណងសមរម្យ និងយុត្តិធម៌ ផ្អែកតាមការសិក្សាតម្លៃជំនួស ពីគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគម្រោងការសាងសង់អគារត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ខាងលើនេះ ។

**មាត្រា៥.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងមហាផ្ទៃ, ក្រសួងទេសចរណ៍ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ព្រមទាំងអភិបាលខេត្តស្វាយរៀង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា៦.-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ


CBF
CASINO & HOTEL UNDER CONSTRUCTION
CASINO & HOTEL 333
MASSAGE 333
LUCKY CASINO 89
Lucky 89 . CASINO
FREE LAND
CUSTOM AND EXCISE
FIELD FARM BELONG TO CUSTOM AND EXISE
PREY VOIR CHECK POINT
Prey Voir Internal Revenue Office
Prey Voir International Border Check Point
CUSTOM&EXCISE
HOUSE
CAMBODIA GATE
To Prey Voir Market
To Prasat Vil Bokvea CASINO Road
EP: 25+491.76
PT: 25+145.71
25+492
25+400
25+300
25+200
ELE: 8.200
5.2963 ha
X=601709.14 Y=1198435.27
X=601638.97 Y=1198442.53
X=601568.87 Y=1198449.79
X=601498.64 Y=1198457.06
X=601490.11 Y=1198513.88
X=601481.58 Y=1198570.71
X=601473.04 Y=1198627.53
X=601464.51 Y=1198684.36
X=601531.85 Y=1198695.94
X=601666.53 Y=1198719.11